**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ និង**
**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
លេខ : ០៤៩ សណន

# សេចក្តីណែនាំរួម
# ស្តីពី
# ការលើកកម្ពស់ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០១១ សណន ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការរៀបចំត្រៀមបម្រើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- យោងសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០២៧ សណន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការពង្រឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- យោងលិខិតក្រសួងមហាផ្ទៃលេខ ១០៦៣ សជណ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២ ស្តីពីការផ្តល់អាទិភាពដល់ការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋនៅតាមឃុំ សង្កាត់តាមប្រតិទិនរបស់ គ.ជ.ប ។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមធ្វើការណែនាំបន្ថែមអំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងរដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម ÷

**១-**ក្រុមប្រឹក្សាឃុំ សង្កាត់នៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស ត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយ និងអនុវត្តនូវលិខិតបទដ្ឋានសំខាន់ៗមួយចំនួន នៅតាមឃុំ សង្កាត់រៀងៗខ្លួន រួមមាន ÷

- ប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំដែលកំណត់ដោយ គ.ជ.ប ។
- សេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០១១ សណន ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការរៀបចំត្រៀមបម្រើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

- សេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០២៧ សណន ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការពង្រឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- លិខិតក្រសួងមហាផ្ទៃ លេខ ១០៦៣ សជណ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២ ស្តីពីការផ្តល់អាទិភាពដល់ការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋនៅតាមឃុំ សង្កាត់ តាមប្រតិទិនរបស់ គ.ជ.ប ។

**២**-ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេស ត្រូវធ្វើការកោះប្រជុំវិសាមញ្ញរៀងរាល់ចុងសប្តាហ៍នីមួយៗ ដើម្បីត្រួតពិនិត្យអំពីវឌ្ឍនភាព បញ្ហាប្រឈមនានា ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សំដៅពិភាក្សាឱ្យបានឯកភាពគ្នាក្នុងការជំរុញដំណើរការនេះឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព មានគុណភាព ស្របតាមច្បាប់ បទបញ្ជា នីតិវិធី និងប្រតិទិនដែលបានកំណត់ ។ រាល់កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ខាងលើនេះ ត្រូវមានកំណត់ហេតុប្រជុំ និងរបាយការណ៍ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្ញើរបាយការណ៍នៃការប្រជុំនេះ០១ច្បាប់ ជូនលេខាធិការដ្ឋានរៀបចំការបោះឆ្នោតរាជធានី ខេត្ត និង០១ច្បាប់ជូនសាលាក្រុង ស្រុក ខណ្ឌសាមី ។

ក្នុងពេលដំណើរការ ករណីមានបញ្ហាប្រឈមណាមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ ឬស្មៀនឃុំ សង្កាត់មិនអាចដោះស្រាយបាន មេឃុំ ចៅសង្កាត់ ឬស្មៀនឃុំ សង្កាត់ត្រូវទំនាក់ទំនងជាបន្ទាន់ជាមួយលេខាធិការដ្ឋានរៀបចំការបោះឆ្នោតរាជធានី ខេត្ត ដើម្បីសហការសម្របសម្រួលគាំទ្រ ។

**៣**-គណៈអភិបាលរាជធានី ខេត្ត គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់ផ្តល់កិច្ចសហការគាំទ្រដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ស្របតាមច្បាប់ បទបញ្ជា នីតិវិធី និងសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**៤**-ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតរាជធានី ខេត្ត ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ មេភូមិ និងប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តសេចក្តីណែនាំរួមនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១២

| | |
|---|---|
| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត<br>ប្រធាន |
| ស ខេង | ទេព នីថា |